ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ ៥៤៥ ក្រ.ប "ផ"
ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ៥៤០
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ៥៣៣
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ១៤៩៧
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៤និង០០នាទីរសៀល នៅសាលសវនាការទី៥ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រីចៅក្រម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកអនុប្រធាន [redacted] ចៅក្រមប្រឹក្សា
លោកចៅក្រម [redacted] ចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៤០ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តកណ្តាល មុខរបរលីបង្ហែ ឪពុកឈ្មោះ [redacted] ថា (រ) ម្តាយឈ្មោះ [redacted] សាម៉ែត (រ) នៅលីវ ជាអធីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨៩៦"ដ"ដឃដ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ នៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ត្រូវបានជាប់ចោទពីបទ លួច (កង់) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ [redacted] ស៊ាងសៀវលាង ភេទស្រី អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅផ្ទះលេខ១២ ផ្លូវលេខ ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១៦ និង៣០នាទី នៅចំណុចមុខផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ មានករណី លួច (កង់) ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ភេទប្រុសអាយុ១៧ឆ្នាំបានធ្វើសកម្មភាពលួចកង់មួយគ្រឿងម៉ាក TREK ពណ៌ក្រហមលាយទឹកក្រូចរបស់ជន

Scanned with CamScanner

រងគ្រោះឈ្មោះ [redacted] សាងសៀវណង ដែលទុកនៅមុខផ្ទះរួចជិះបានបន្តិចក៏ត្រូវបានម្ចាស់ឃើញទាន់ស្រែក "ចោរៗ" ។ ស្របពេលមានសមត្ថកិច្ចល្បាតក្បែរនោះ ក៏បានចាប់ខ្លួនតែម្តង។

-បានឃើញរបាយការណ៍សរុបលេខ២៣/២០២២រ.ប.ក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៥២១ អ.ឃ.ឋ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ១៣២៧ អ.ឃ.ឋ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៧៥២"ដ"ដ.ដ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បានឆ្លើយថា៖ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៦ និង៣០នាទី ខ្លួនបានដើរចេញពីផ្សារដើមគរដើម្បីទៅអូសរទេះនៅផ្សារនាគមាស ដោយខ្លួនដើរតាមប្រឡាយទឹកស្អុយ ។ ពេលដើរមកដល់ចំណុចកើតហេតុ ខ្លួនឃើញកង់០១គ្រឿងម៉ាក TREK ពណ៌ក្រហមលាយទឹកក្រូចទុកនៅមុខផ្ទះ ។ ពេលនោះ ខ្លួនក៏ធ្វើសកម្មភាពលួចយកកង់ ហើយជិះបានបន្តិច ក៏ត្រូវម្ចាស់គេស្រែក "ចោរៗ" ។ ពេលនោះមានប្រជាពលរដ្ឋចាប់រូបខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង។

-អំណាងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សាងសៀវណង បានឆ្លើយថា៖កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៦និង៣០នាទី ខ្លួនបានបណ្តើរកង់ចេញពីក្នុងផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ គោលបំណងជិះហាត់ប្រាណ ។ ពេលនោះ ខ្លួនទុកកង់នៅមុខផ្ទះ ហើយដើរចូលទៅក្នុងផ្ទះពាក់ស្បែកជើង ។ ពេលនោះ ស្រាប់តែមានជនសង្ស័យមកលួចកង់នោះ រួចជិះគេចខ្លួនតាមបណ្តោយផ្លូវល្បឿនទឹកស្អុយ ។ ឃើញដូចនេះ ខ្លួនរត់ដេញតាមពីក្រោយ ហើយស្រែក "ចោរៗ" ។ ពេលនោះ មានសមត្ថកិច្ច និងប្រជាពលរដ្ឋចាប់ជនល្មើសបាន ហើយដកហូតកង់មកឱ្យខ្លួនវិញ។

-តាមអំណាងរបាយការណ៍សរុបលេខ២៣/២០២២របក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញបញ្ជាក់ថា៖ ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើលួច (កង់) ជារបស់ជនរងគ្រោះឈ្មោះ [redacted] សាងសៀវណង កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១៦ និង៣០នាទី នៅចំណុចផ្ទះលេខ១២ ផ្លូវលេខ២៧០ ភូមិ៩ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រាកដមែន។

សេចក្តីសន្និដ្ឋានស្តីចសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ជនជាប់ចោទបានសារភាពថាខ្លួនពិតជាបានលួចកង់នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ប្រាកដមែន ។ តំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៣២៧ អ.ឃ.ឋ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២។

Scanned with CamScanner

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វិទ្ធ បានធ្វើសេចសន្និដ្ឋានថា៖ ក្រោយការសួរដេញដោលឃើញថា កូនក្តីខ្លួនបានសារភាពទទួលកំហុសដោយស្មោះត្រង់ ។ ការប្រព្រឹត្តរបស់កូនក្តីខ្លួនដោយសារស្ថានភាពគ្រួសារក្រីក្រ,កូនក្តីខ្លួនមានចំណេះដឹងតិចតួច និងមានការស្តាយក្រោយនូវកំហុសដែលបានប្រព្រឹត្តកន្លងមក ។ ម៉្យាងទៀត កូនក្តីខ្លួនជាអនីតិជន ។ ដូច្នេះ ខ្លួនសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] វិទ្ធ និយាយសម្តីចុងក្រោយថា៖ខ្លួនសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឃើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិទ្ធ មានភាពស៊ីសង្វាក់គ្នាទៅនឹងអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សាងសៀវណាង ព្រមទាំងភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១៦និង៣០នាទី ជនជាប់ចោទឈ្មោះ [redacted] វិទ្ធ ពិតជាបានធ្វើសកម្មភាពលួចកង់មួយគ្រឿងម៉ាក TREK ពណ៌ក្រហមណាយទឹកក្រូចរបស់ជនរងគ្រោះឈ្មោះ [redacted] សាងសៀវណាង ដែលទុកនៅមុខផ្ទះនៅចំណុចមុខផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ [redacted] វិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ជាអនីតិជន ជាកំណត់អាយុស្ថិតក្នុងការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណណាមួយដែលនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ។ ដូចនេះ ជនជាប់ចោទប្រាកដជាយល់ដឹងថាអំពើល្មើសរបស់ខ្លួនពិតជាប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។

៣-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វិទ្ធ បានប្រព្រឹត្តអំពើលួចយកកង់របស់ជនរងគ្រោះឈ្មោះ គា សាងសៀវណាង ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើរបស់ជនជាប់ចោទនេះ ចាត់ជាបទលួចដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៤-តំណាងអយ្យការបានសេចក្តីសន្និដ្ឋានប្តឹងសុំថា៖សុំរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៣២៧ អ.ឃ.ឋ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ និងសូមឲ្យតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ ការសន្និដ្ឋានប្តឹងសុំនេះ គប្បីតុលាការពិចារណា។

៥-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បានធ្វើសេចសន្តិដ្ឋានថា៖ ខ្លួនសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។ ការសន្តិដ្ឋាននេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

៦-មានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដើម្បីប្រកាសពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ លួច (កង់) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៧-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធ បានឱ្យឃាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន។ ការស្នើសុំនេះមានលក្ខណៈសមហេតុផល ព្រោះជនជាប់ចោទជាអនីតិជន ហើយបានសារភាពទោសកំហុសដោយស្មោះត្រង់ គប្បីតុលាការលើកយកមកពិចារណា និសម្រេចតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៨-ជនរងគ្រោះឈ្មោះ [redacted] ស៊ាងសៀវណាង បានទទួលកង់យកទៅប្រើប្រាស់វិញហើយ និងពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីប្តឹងទាមទារសំណងរដ្ឋប្បវេណីទេ ។ ហេតុនេះ គប្បីតុលាការពុំគប្បីលើកយកមកធ្វើការពិចារណាឡើយ។

<u>ហេតុដូច្នេះសម្រេច</u>

-ផ្តន្ទាទោសឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៩ (ប្រាំបួន) ខែ ពីបទ លួច (កង់) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១២ ផ្លូវលេខ២៧០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៣៥៣,មាត្រា៣៥៦ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ក្រឡាបញ្ជីសវនាការ **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខានិងត្រា: [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]